ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

BSDA

BUDDHISM FOR SOCIAL DEVELOPMENT ACTION ORGANIZATION

# គោលនយោបាយទំនាស់ផលប្រយោជន៍

## Conflict of Interest Policy

2024

កែប្រែលើកទី៦

| **មាតិកា**<br>Content | **ទំព័រ**<br>Page |
| --- | --- |


អំពីអង្គការ BSDA.....................................................................................................៣

ប្រការ១.និយមន័យ.....................................................................................................៥

ប្រការ២.វិសាលភាព...................................................................................................៥

ប្រការ៣.គោលបំណង..................................................................................................៥

ប្រការ៤.បទបញ្ញាត្តិទូទៅ.............................................................................................៥

ប្រការ៥.ទំនាស់នៅពេលមានការផ្តល់ជាកាដូ ជាកម្រៃជើងសារ ឬសំណូក............................៦

ប្រការ៦.ទំនាស់ជាមួយផលប្រយោជន៍ហិរញ្ញវត្ថុ................................................................៦

ប្រការ៧.ទំនាស់ជាមួយផលប្រយោជន៍ផ្ទាល់ខ្លួន..................................................................៦

ប្រការ៨.ការមិនផ្សព្វផ្សាយទំនាស់លើផលប្រយោជន៍..........................................................៦

ប្រការ៩.បុគ្គលិកមិនត្រូវពាក់ព័ន្ធជាមួយសកម្មភាពណាមួយដូចខាងក្រោម...........................៧

# សេចក្តីផ្តើម

## សាវតាររបស់ BSDA

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍសង្គម(BSDA) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៥ ដោយព្រះសង្ឃ ៧អង្គ នៅវត្តនគរបាជ័យ។ក្រសួងមហាផ្ទៃបានទទួលស្គាល់BSDAតាមរយៈលេខ១៦២ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ។ BSDAមិនធ្វើការបម្រើឱ្យគណបក្សនយោបាយណាឬក៏ផ្សព្វផ្សាយពីសាសនារបស់សមាជិកខ្លួនឡើយ។

អង្គការ BSDA គឺផ្តោតតែលើការអភិវឌ្ឍសង្គម និងជួយប្រជាជនក្រីក្របំផុតដែលកំពុងរស់ក្នុងសហគមន៍ក្រីក្រ។

## អត្តសញ្ញាណ

ស.ព.អ.ស ជាអង្គការសហគមន៍បានបង្កើតឡើងនៅលើ គោលការណ៍ព្រះពុទ្ធសាសនានៃធម៌មេត្តា ដើម្បីផ្តល់អំណាចដល់ប្រជាជនដែលងាយរងគ្រោះ និងដើម្បីលើកកម្ពស់ការចូលរួមទំនាក់ទំនងល្អក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីរួមចំណែកលុបបំបាត់នៃភាពរងគ្រោះឬក្រីក្រ។

## គុណតម្លៃ

ជាឫសគល់ក្នុងការបង្រៀនរបស់ព្រះពុទ្ធដោយអនុវត្តធម៌មេត្តាBSDA បានប្រកាន់ខ្ជាប់និងលើក កម្ពស់គុណតម្លៃរបស់ខ្លួនដូចខាងក្រោម:

- បម្រើអ្នកក្រីក្រៈកែលម្អជីវភាពរស់នៅរបស់គ្រួសារអ្នកក្រីក្រ។
- សាមគ្គីភាពៈកសាង ជំនឿជាក់ ភាពស្មោះត្រង់ និងការគោរពគ្នាដូចជាគ្រួសារ។
- លទ្ធិប្រជាធិបតេយ្យៈលើកកំពស់សំលេងរួមពីសហគមន៍ អ្នកពាក់ព័ន្ធ និងបុគ្គលិក គ្រប់លំដាប់ថ្នាក់នៅក្នុងដំណើរការធ្វើការសេចក្តីសម្រេចអ្វីមួយ។
- នវានុវត្តន៍: ការផ្តល់នូវឱកាសតែមួយគត់សម្រាប់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយបញ្ហារបស់ពួកគេ តាមរយៈព័ត៌មានបច្ចេកវិទ្យាគមនាគមន៍ (ICT) និងការគិតត្រិះរិះពិចារណា។
- សុចរិតភាព និងគណនេយ្យភាពៈនៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ! ត្រូវបានទទួលខុសត្រូវខ្ពស់ និងមានតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ។

## ទស្សនៈវិស័យ

អង្គការ ស.ព.អ.ស ចង់ឃើញសង្គមដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យនិងអាចចិញ្ចឹមជីវិតបានដោយខ្លួនឯង។

## បេសកកម្ម

ស.ព.អ.ស គឺដើម្បីជំរុញ និងលើកកម្ពស់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះ ជាពិសេសស្ត្រីកុមារ និងយុវជន តាមរយៈវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រាសសង្គម អភិបាលកិច្ចល្អ និងការផ្តួចផ្តើមអភិវឌ្ឍន៍ជីវភាពរស់នៅ និងកម្មវិធីនវានុវត្តន៍ជាដៃគូជាមួយអ្នកផ្សេងៗ។

## ទិសដៅជាយុទ្ធសាស្ត្រ

- អនុវត្តន៍កម្មវិធីចម្រុះ និងប្រកបដោយភាពច្នៃប្រឌិត
- ការបង្កើតទំនាក់ទំនងរឹងមាំ
- ការប្រកបមុខរបរស់នៅប្រកបដោយនិរន្តរភាព
- ការបង្កើតយុទ្ធសាស្ត្រគៀគរថវិកាប្រកបដោយនិរន្តរភាព
- បន្តការរៀន និងរីកចម្រើន
- ការកសាងសមត្ថភាពបុគ្គលិក

## គោលបំណង

ដើម្បីធានានិរន្តរភាព គណនេយ្យភាពតម្លាភាព សុវត្ថិភាពបុគ្គលិកនិងភាពត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## វិសាលភាព

គោលនយោបាយនេះអនុវត្តទៅលើថ្នាក់ដឹកនាំនិងបុគ្គលិករបស់អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គមទូទាំងប្រទេសកម្ពុជា។

**ប្រការ១.និយមន័យ**

ទំនាស់ផលប្រយោជន៍ជាទឹកប្រាក់ ឬ ផលប្រយោជន៍ការងារសម្រាប់គ្រួសារ និង ខ្លួនដែលអាចមានឥទ្ធិពលទៅលើជនណាម្នាក់ ក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន។

**ប្រការ២.វិសាលភាព**

គោលនយោបាយទំនាស់ផលប្រយោជន៍មានដែនកំណត់ សម្រាប់អង្គការដូចជា សមាជិកក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ បុគ្គលិកគម្រោង និងបុគ្គលិកប្រតិបត្តិការជាដើម។

**ប្រការ៣.គោលបំណង**

ទំនុកចិត្តពីសាធារណចំពោះសេចក្តីថ្លៃថ្នូររបស់ BSDA គឺមានសារសំខាន់ចំពោះ ការអនុវត្តសមរម្យរបស់ខ្លួន។ ទំនុកចិត្តអាចត្រូវបានបំផ្លាញ ប្រសិនបើសាធារណជន ឬអ្នកពាក់ព័ន្ធកត់សម្គាល់ឃើញទំនាស់លើផលប្រយោជន៍។ បុគ្គលិករបស់ BSDA ដែលរួមបញ្ចូលទាំងនិយោជិត អ្នកស្ម័គ្រចិត្ត និងអ្នកប្រឹក្សារយៈពេលវែង ត្រូវដឹងថា ផលប្រយោជន៍ឯកជនរបស់ពួកគេ ទាំងផ្នែកហិរញ្ញវត្ថុ និងបញ្ហាផ្ទាល់ខ្លួនអាចមានប៉ះទង្គិចជាមួយភារកិច្ចរបស់ពួកគេ។ គោលនយោបាយនេះគឺដើម្បីធានាថា BSDAរក្សាអព្យាក្រឹតក្នុងការបំពេញមុខងាររបស់ខ្លួន ក្នុងលក្ខណៈមិនលំអៀង និងប្រកបដោយវិជ្ជាជីវៈជាមួយស្តង់ដារសីលធម៌ខ្ពស់។

**ប្រការ៤.បទបញ្ញាត្តិទូទៅ**

ក. បុគ្គលិកដែលចុះហត្ថលេខា ធ្វើតាមគោលការក្នុងគោលនយោបាយនេះ ត្រូវយល់ព្រមធ្វើតាមគោលនយោបាយទំនាស់ផលប្រយោជន៍។

ខ. បុគ្គលិកគួរបំពេញភារកិច្ចនៃមុខដំណើររបស់គាត់/នាងដោយមិនលំអៀង និងមិនទទួលឥទ្ធិពលពី ភាពភ័យខ្លាច ឬការចូលចិត្ត។

**ការផ្សព្វផ្សាយទំនាស់ផលប្រយោជន៍**

ក.បុគ្គលិកមានភារកិច្ចក្នុងការបង្ហាញប្រាប់ពីៈ

- ទំនាស់លើផលប្រយោជន៍ដែលមាន (ដែលអាចកើតមានដែលអាចឃើញជាក់ស្តែង ឬដែលមានសក្តានុពល)
- លក្ខណៈរបស់ជម្លោះលើផលប្រយោជន៍ នៅពេលណាគាត់ ឬនាងបានដឹងថា ជម្លោះពិតជាមាន ឬថា វាមានមូលហេតុសមរម្យដែលអាចកើតមាន។

ខ.បុគ្គលិកគួរនិយាយទៅកាន់ អ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេ ប្រសិនបើមានទំនាស់លើផលប្រយោជន៍។ប្រសិនបើអ្នកគ្រប់គ្រង ជាផ្នែកមួយនៃទំនាស់ សមាជិកបុគ្គលិកគួរនិយាយទៅកាន់នាយក/នាយិកាប្រតិបត្តិ ឬ សមាជិកគណៈកម្មាការដឹកនាំណាម្នាក់។

គ.អ្នកគ្រប់គ្រងនឹងសម្រេចពីរបៀបដោះស្រាយ ទំនាស់ផលប្រយោជន៍ក្នុងស្ថានការណ៍ជាក់ស្តែងនៃទំនាស់។ នៅពេលណាដែលមានទំនាស់ផលប្រយោជន៍កើតឡើង បុគ្គលិកដែលទទួលរងឥទ្ធិពលនឹងមិនចូលរួមក្នុងការពិភាក្សាពីបញ្ហាដែលបានផ្តល់ចំពោះជម្លោះនោះទេ។

**ប្រការ៥.ទំនាស់នៅពេលមានការផ្តល់ជាកាដូ ជាកម្រៃជើងសារ ឬសំណូក**

បុគ្គលិក BSDA ត្រូវបានហាមឃាត់យ៉ាងដាច់ខាតពីការសុំ ឬទទួលយកថ្លៃទឹកតែ ឬវត្ថុផ្សេងៗ ដែលមានទម្រង់ជាប្រាក់មានតម្លៃលើសពី១០ដុល្លារពីអ្នកផ្គត់ផ្គង់ អ្នកទទួលការងារ អ្នកទទួលផល ឬបក្ស ពួកចំពោះការយល់ព្រមបន្ទាប់បន្សំ។ វាត្រូវបានអនុញ្ញាតក្នុងការទទួលយកកាដូដែលមិនមានទម្រង់ ជាប្រាក់ ដូចជាៈ ប្រតិទិន អាហារ ឬសិប្បកម្មដែលមិនមានតម្លៃថ្លៃ។ កាដូទាំងនោះត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិរបស់ BSDA។

**ប្រការ៦.ទំនាស់ជាមួយផលប្រយោជន៍ហិរញ្ញវត្ថុ**

ផលប្រយោជន៍ហិរញ្ញវត្ថុអាចគ្របដណ្តប់របស់ដូចជា តំណែងជានាយក ការកាន់កាប់ភាគហ៊ុន អចលទ្រព្យ ឬសេចក្តីទុកចិត្តដែលមានសក្តានុពល ចំពោះទំនាស់ជាមួយមុខតំណែង របស់ពួកគេ។ ឧទាហរណ៍នៃប្រភេទជម្លោះបែបនេះមានដូចជាៈ

- និយោជិតដែលអ្នកម្ចាស់នៃអាគារដែល BSDA ពិចារណាចង់ជួល
- សមាជិកបុគ្គលិក ដែលគាំទ្រថវិកាជាក់លាក់មួយចំនួន ព្រោះគាត់/នាងនឹងទទួលផលដោយការទទួលជំនួយ ឬដោយការចូលរួមក្នុងការអនុវត្តនៃគម្រោងនេះ។

**ប្រការ៧.ទំនាស់ជាមួយផលប្រយោជន៍ផ្ទាល់ខ្លួន**

ផលប្រយោជន៍ផ្ទាល់ខ្លួននិងផ្សេងៗទៀតអាចរាប់បញ្ចូលទាំងឪពុកម្តាយទំនាក់ទំនងរ៉ូមែនទិក ឬផ្សេ-ងៗ។ឧទាហរណ៍នៃទំនាស់រវាងផលប្រយោជន៍ផ្ទាល់ខ្លួនឬផ្សេងៗទៀតជាមួយនឹងភារកិច្ចការងាររួមមានៈ

- និយោជិត BSDA ក្នុងក្រុមជ្រើសរើសដែលមានទំនាក់ទំនង បុគ្គលជាមួយបេក្ខជន ដែលដាក់ពាក្យសម្រាប់មុខដំណែង។
- អ្នកប្រឹក្សាដែលត្រូវបានសុំឱ្យ មកធ្វើជាគណៈកម្មាការពិនិត្យការដេញថ្លៃ ប៉ុន្តែរៀបការជាមួយអ្នកដេញថ្លៃណាម្នាក់

**ប្រការ៨.ការមិនផ្សព្វផ្សាយទំនាស់លើផលប្រយោជន៍**

វាមិនមានអ្វីខុសឆ្គងចំពោះការមានទំនាស់ផលប្រយោជន៍នោះទេ ហើយបុគ្គលិកនឹងមិនទទួលរងអ្វីពីការរាយការណ៍បញ្ហានេះដែរ។បញ្ហាកើតឡើងនៅពេលសមាជិកបុគ្គលិកមិនរាយការណ៍ពីទំនាស់ផលប្រយោជន៍ដែលពិតប្រាកដ ដែលមានសក្តានុពល ឬដែលអាចមើលឃើញ ហើយចូលរួមក្នុងការសម្រេចចិត្តនៅពេល ដែលជម្លោះអាចជះឥទ្ធិពលដល់សេចក្តីសម្រេចរបស់បុគ្គលណាម្នាក់។ ក្នុងករណីដែលនិយោជិតបានខកខានមិនរាយការណ៍ពីទំនាស់លើផលប្រយោជន៍ៈ

- ប្រសិនបើការសម្រេចចិត្តត្រូវបានធ្វើឡើង នៅពេលអ្នកចូលរួម មានទំនាស់ផលប្រយោជន៍ អ្នកគ្រប់គ្រង ឬនាយកប្រតិបត្តិអាចប្រកាសការសម្រេចចិត្តទុកជាមោឃៈ ហើយត្រូវធ្វើការសម្រេចចិត្តជាថ្មី ឬបោះឆ្នោតដោយមិនមានវត្តមានរបស់សមាជិកដែលទទួលរងឥទ្ធិពល។
- ការខកខានរបស់និយោជិត ក្នុងការប្រកាសពីទំនាស់ផលប្រយោជន៍ ឬ ធ្វើតាមគោលនយោបាយនេះអាចបង្កើតជាការប្រព្រឹត្តិខុសឆ្គងយ៉ាងធ្ងន់ធ្ងរ ហើយអាចនាំទៅរកសកម្មភាពវិន័យសមរម្យដើម្បីប្រឆាំងនឹងនិយោជិត រហូតដល់ការបញ្ឈប់ពីការងារ។

**ប្រការ៩.បុគ្គលិកមិនត្រូវចពាក់ព័ន្ធជាមួយសកម្មភាពណាមួយដូចខាងក្រោម**

- ចចារតម្លៃជាមួយអ្នកលក់ ឬអ្នកទទួលការងារសម្រាប់ទំនិញ ឬសេវាកម្មក្នុងនាមរបស់BSDA សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។
- ទទួលប្រាក់ទឹកតែ កាដូ ឬការឧបត្ថម្ភពីអ្នកលក់ ឬអ្នកផ្តល់សេវាកម្មដល់ BSDA។
- ទទួលកាដូ ការឧបត្ថម្ភ ឬលុយពីអ្នកទទួលផលសម្រាប់សេវាកម្មដែលផ្តល់ឱ្យ ឬដើម្បីបង្កើន ការទទួលសេវាកម្មពីបុគ្គលិក BSDA។
- ជួល ឬទិញទំនិញសម្រាប់សាច់ញាតិ
- រក្សាទុកការបញ្ចុះតម្លៃពីអ្នកលក់ ឬអ្នកផ្តល់សេវាកម្មសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។

ខ្លឹមសារ ឬបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងគោលនយោបាយខាងលើត្រូវទុកជានិរាករណ៍។

ថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

កំពង់ចាម ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២៤

| | |
|---|---|
| **ហត្ថលេខា** | **ហត្ថលេខា** |
| **ឃឺត ប្រ៊ីដេនប៊ឺក** | **ឈុន ស្រស់** |
| Kurt Bredenberg | Chhon Srors |
| **ប្រធានក្រុមប្រឹក្សាភិបាល** | **នាយិកាប្រតិបត្តិ** |
| Chairman of Board of Director | Executive Director |